# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាប្រសិទ្ធីពរលើរូបសំណាកទេវទូតនៅព្រះសហគមន៍ព្រះកុមារយេស៊ូ
# ទឹកទំពុន ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២០

## យកព្រះយេស៊ូជាគំរូសម្រាប់សេចក្តីស្រឡាញ់របស់យើង

**អត្ថបទទី១៖ សេរីភាព ២២,២០-២៦**

ប្រសិនបើអ្នកឲ្យជនទុគ៌តណាម្នាក់ ក្នុងចំណោមប្រជាជនរបស់យើងខ្ចីប្រាក់ មិនត្រូវប្រព្រឹត្ត ចំពោះគេដូចជាអ្នកចងការប្រាក់ឡើយ គឺកុំទារការប្រាក់ពីគេជាដាច់ខាត។ សរ ២២,២៤

**អត្ថបទទី២៖ ថេស្សាឡូនិកទី១ ១,៥-១០**

បងប្អូនបានយកតម្រាប់តាមយើង និងយកតម្រាប់តាមព្រះអម្ចាស់ គឺទោះបីបងប្អូនជួបប្រទះ នឹងទុក្ខវេទនាធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ក៏បងប្អូនបានទទួលព្រះបន្ទូលទាំងមានអំណរមកពី ព្រះវិញ្ញាណដ៏វិសុទ្ធដែរ។ ១ថស ១,៦

**ដំណឹងល្អ៖ ម៉ាថាយ ២២,៣៤-៤០**

តើមានបទបញ្ញាណាសំខាន់ជាងគេ? មថ ២២,៣៦

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ជាឱកាសមួយដើម្បីសុំឲ្យព្រះជាម្ចាស់ប្រទានពរលើទេវទូតទាំងពីរ ក្នុងព្រះវិហារនេះមានទេវទូតច្រើនដែលមើលមិនឃើញ។ ដោយសារ យើងម្នាក់ៗយើងមានទេវទូតមួយដែលការពារថែរក្សាជីវិតរបស់យើង ដើម្បីឲ្យយើងយកចិត្តទុកដាក់រស់នៅតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ទេវទូតទាំឡាយយើងមើលមិនឃើញ ប៉ុន្តែយើងដឹងថានៅជាមួយយើងពីថ្ងៃទៅមួយថ្ងៃដើម្បីការពារយើង។ ទេវទូត ជាទូតរបស់ព្រះជាម្ចាស់ដែលយើងស្គាល់ឈ្មោះខ្លះៗដូចជា មីកាអែល រ៉ាហ្វាអែល កាព្រីអែល យើងស្គាល់ច្បាស់ជាងគេ ព្រោះជាទេវទូតដែលបានជូនដំណឹងរបស់ព្រះជាម្ចាស់ទៅព្រះនាងម៉ារី ធ្វើជាមាតារបស់ព្រះជាម្ចាស់។ នៅទីនេះ យើងមានទូតច្រើនទៀតដែលបានចូលរួមសិក្ខាសាលាអំពី ការផ្សព្វផ្សាយព័ត៌មានកាតូលិក ពីរថ្ងៃកន្លងមក។ ថ្ងៃនេះឲ្យគេសរសេរអត្ថបទខ្លីៗ ថតរូបខ្លះៗ ដើម្បីឲ្យគេធ្វើជាទេវទូតរបស់ព្រះជាម្ចាស់ដែលប្រកាសដំណឹងល្អ ផ្តល់សក្ខីភាពអំពីជីវិតនៃព្រះសហគមន៍របស់យើង មិនមែនតែសម្រាប់គ្នាយើង គឺសម្រាប់ប្រទេសកម្ពុជានិងពិភពលោកទាំងមូល។

ព្រឹកនេះ ដែលយើងមានឱកាសជួបជុំគ្នាអធិដ្ឋាន អរព្រះគុណព្រះជាម្ចាស់ថ្ងៃអាទិត្យ ជាឱកាសមួយដើម្បីចាប់ផ្តើមឆ្នាំសកម្មភាពសាជាថ្មី។ យើងអាចនិយាយថា ជីវិតរបស់យើងចាប់ផ្តើមសាជាថ្មី ដោយសារតាំងពីខែមីនារហូតដល់ខែតុលានេះ ព្រះសហគមន៍របស់យើងបានកាត់បន្ថយសកម្មភាពច្រើន កាត់បន្ថយការជួបជុំគ្នា កាត់បន្ថយការអប់រំ...។ ប៉ុន្តែ នៅពេលនេះបីដូចជា

យើងពោរពេញដោយកម្លាំង ដែលត្រូវតែសួរសំណួរមួយដ៏សំខាន់បំផុតគឺ **តើយើងដែលជាគ្រីស្គបរិស័ទនៅក្នុងភូមិ នៅក្នុងទីតាំងដែលយើងនៅ យើងធ្វើដូចម្តេចដើម្បីឲ្យជំនឿរបស់យើង សេចក្តីសង្ឃឹមរបស់យើង សេចក្តីស្រឡាញ់របស់យើង អាចផ្តល់សក្ខីភាពដល់បងប្អូននៅក្នុងទីតាំងរបស់យើងបាន?** យើងមិនគិតដល់ទូទាំងប្រទេសឬពិភពលោក ប៉ុន្តែគិតអំពីជីវិតរបស់យើងផ្ទាល់។ ព្រះសហគមន៍មានវត្តមាននៅទីនេះដែលមានសកម្មភាពច្រើន គ្រប់សកម្មភាពដែលយើងមាន គ្រប់ការអធិដ្ឋានដែលយើងមាន **តើមានឥទ្ធិពលអ្វីខ្លះ ដើម្បីបំភ្លឺបងប្អូនដែលរស់នៅក្នុងភូមិរបស់យើង?**

អត្ថបទទីពីរ បានជួយឲ្យយើងយល់អំពីតួនាទីរបស់យើង លោកប៉ូលកំពុងសរសើរក្រុមគ្រីស្គបរិស័ទក្រុងថេស្សាឡូនិក។ គ្រីស្គបរិស័ទនេះ មានចំណុចពីរដ៏សំខាន់ដែលណែនាំឲ្យគេផ្តល់សក្ខីភាពប្លែកៗ គឺ "**បងប្អូនបានយកតម្រាប់តាមយើង និងយកតម្រាប់តាមព្រះអម្ចាស់**" បងប្អូនបានយកព្រះជាម្ចាស់ បានយកសន្តប៉ូលជាគំរូដើម្បីផ្តល់សក្ខីភាព។ គេបានផ្តល់សក្ខីភាពដល់មនុស្សយ៉ាងច្រើន "**ហេតុនេះ បងប្អូនបានទៅជាគំរូដល់អ្នកជឿទាំងអស់ ដ្បិតព្រះបន្ទូលរបស់ព្រះអម្ចាស់ដែលចេញពីបងប្អូនទៅនោះ មិនត្រឹមតែលាន់ឮសុសសាយទៅគ្រប់ទីកន្លែង**"។ ហេតុនេះហើយរបៀបដែលបងប្អូនគ្រីស្គបរិស័ទនៅក្រុងថេស្សាឡូនិក គេបានរស់នៅដោយយកលោកប៉ូលជាគំរូ ដោយយកព្រះជាម្ចាស់ជាគំរូបានក្លាយទៅជាគំរូសម្រាប់បងប្អូនឯទៀតៗ នៅគ្រប់ទីកន្លែងពីស្រុកមួយទៅស្រុកមួយ។ សម្រាប់យើង យើងត្រូវការយល់នេះយើងធ្វើដូចម្តេចដើម្បីយកព្រះជាម្ចាស់ទៅជាគំរូ ដើម្បីអនុវត្តជីវិតរបស់យើងជាគ្រីស្គបរិស័ទយ៉ាងជាក់ស្តែង។

ជីវិតរបស់យើងជាគ្រីស្គបរិស័ទយ៉ាងជាក់ស្តែង ខ្ញុំសូមរំលឹកដល់គ្រូអប់រំជំនឿទាំងអស់ដល់ប្អូនៗដែលកំពុងរៀនអប់រំជំនឿ អត្ថបទដែលយើងបានស្តាប់ថ្ងៃនេះថា "**ក្នុងក្រឹត្យវិន័យ តើមានបទបញ្ញាណាសំខាន់ជាងគេ? ព្រះយេស៊ូមានព្រះបន្ទូលថា៖ (ត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នក ឲ្យអស់ពីចិត្តគំនិត អស់ពីស្មារតី និងអស់ពីប្រាជ្ញា) ហ្នឹងហើយជាវិន័យទីមួយ ដែលសំខាន់ជាងគេបំផុត។ រីឯវិន័យទីពីរក៏សំខាន់ដូចគ្នាដែរ (គឺត្រូវស្រឡាញ់បងប្អូនឯទៀតៗ ឲ្យបានដូចស្រឡាញ់ខ្លួនឯង)**"។ នេះសម្រាប់យើងមិនទាន់ល្មមទេ ដោយសារព្រះយេស៊ូកំពុងឆ្លើយទៅធម្មាចារ្យដែលកំពុងរស់នៅក្នុងបរិយាកាសសម្ពន្ធមេត្រីចាស់ ដូច្នេះព្រះយេស៊ូរំលឹកអំពីធម្មវិន័យរបស់លោកម៉ូសេ។ នេះមិនទាន់ល្មមទេ ដោយសារព្រះយេស៊ូយាងមកដើម្បីណែនាំឲ្យធម្មវិន័យរបស់លោកម៉ូសេរកឃើញអត្ថន័យដ៏ពេញលក្ខណៈ គឺរកឃើញនៅពេលព្រះយេស៊ូសោយទិវង្គត និងមានព្រះអង្គមានជន្មរស់ឡើងវិញ។ យើងទាំងអស់គ្នា ដែលជាប្រជារាស្ត្ររបស់ព្រះយេស៊ូគ្រីស្គ ដែលមានព្រះជន្មគង់នៅសព្វថ្ងៃ យើងមិនមែនជាប្រជារាស្ត្រនៃសម្ពន្ធមេត្រីចាស់ យើងជា

ប្រជារាស្ត្ររបស់ព្រះយេស៊ូគ្រីស្ទដែលមានព្រះជន្មរស់ឡើងវិញ។ មុនព្រះយេស៊ូសោយទិវង្គត នៅពេលព្រះយេស៊ូជួបជាមួយក្រុមគ្រីស្តទូតចុងក្រោយបំផុត នៅពេលលោកយ៉ូដាស់អ៊ីស្ការីយ៉ុត ក្បត់ព្រះយេស៊ូ ព្រះអង្គនៅសល់តែ១១នាក់នៅជាមួយ។ នៅពេលនោះ ព្រះយេស៊ូបានប្រទាន ធម្មវិន័យរបស់ព្រះអង្គ ដែលជាធម្មវិន័យបំពេញឲ្យធម្មវិន័យរបស់លោកម៉ូសេដែលយើងបានស្តាប់ថ្ងៃនេះ "**សូមស្រឡាញ់គ្នាទៅវិញទៅមកដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នា**"។ មានន័យថា សម្រាប់យើងដែលជាគ្រីស្តបរិស័ទយើងត្រូវតែស្រឡាញ់បងប្អូនឯទៀតៗតាមរបៀបព្រះយេស៊ូ ដោយយកព្រះយេស៊ូជាគំរូ។ ដូចលោកប៉ូលបានរំលឹកនៅក្នុងអត្ថបទទីពីរថា "**យកព្រះយេស៊ូជាគំរូសម្រាប់សេចក្តីស្រឡាញ់របស់យើង**"។ មូលដ្ឋានគឺស្រឡាញ់ព្រះជាម្ចាស់អស់ពីដួងចិត្ត មូលដ្ឋានគឺស្រឡាញ់ផ្ទាល់ខ្លួន ប្រសិនបើយើងមិនចេះស្រឡាញ់ខ្លួនឯងយើងស្រឡាញ់អ្នកដទៃដូចម្តេចបាន។ ប៉ុន្តែ សេចក្តីស្រឡាញ់របស់យើងពេញលក្ខណៈ នៅពេលយើងនឹកឃើញអំពីរបៀបព្រះយេស៊ូដែលណែនាំឲ្យយើងចេះស្រឡាញ់គ្នាទៅវិញទៅមកតាមរបៀបរបស់ព្រះអង្គ។ គ្រូអប់រំជំនឿកុំភ្លេចណែនាំឲ្យប្អូនៗដែលទទួលការអប់រំជំនឿពីយើង ចូលនៅក្នុងធម្មវិន័យរបស់ព្រះយេស៊ូយ៉ាងជាក់ស្តែង ដើម្បីទៅជាកម្លាំងដឹកនាំជីវិតរបស់យើងពីមួយថ្ងៃទៅមួយថ្ងៃ ក្នុងការអនុវត្តអត្ថបទទីមួយដែលថា "**យើងគ្មានសិទ្ធិណែនាំឲ្យកុមារកំព្រា ស្ត្រីមេម៉ាយ បាត់បង់សេចក្តីសង្ឃឹម**"។ ថ្ងៃនេះ ជាបុណ្យសន្តីតេរីសា ជាសន្តីនៅក្នុងសតវត្សរ៍ទីមួយ ជាស្ត្រីម្នាក់ដែលបានធ្វើដំណើរជាមួយក្រុមគ្រីស្តទូត ហើយបានទទួលតួនាទីដើម្បីយកចិត្តទុកដាក់ជាមួយស្ត្រីមេម៉ាយ កុមារកំព្រា អ្នកតូចតាចដែលគ្មានទីពឹង។

សម្រាប់យើងដែលជាគ្រីស្តបរិស័ទ នៅពេលយើងភ្ជាប់ជាមួយធម្មវិន័យរបស់ព្រះយេស៊ូដែលជាកម្លាំង ដែលជាគោលដៅ ដើម្បីអនុវត្តនៅក្នុងជីវិតរបស់យើងយ៉ាងជាក់ស្តែង។ យើងអាចរួមរស់ជាព្រះសហគមន៍របស់ព្រះអង្គ ដែលយកចិត្តទុកដាក់ជាមួយស្ត្រីមេម៉ាយ ជាមួយកុមារកំព្រា ជាមួយមនុស្សទាំងអស់ដែលបាត់បង់សេចក្តីសង្ឃឹមនៅក្នុងជីវិត ព្រះសហគមន៍មិនខ្វះឱកាសដើម្បីអនុវត្តតាម។ កុំឲ្យធម្មវិន័យដែលយើងយកព្រះយេស៊ូជាគំរូ ទៅជាចំណេះដឹងដែលយើងអាចឆ្លើយនៅពេលមានសំណួរ ប៉ុន្តែទៅជាកម្លាំង ទៅជាអាទិភាព ដើម្បីដឹកនាំជីវិតរបស់យើងពីមួយថ្ងៃទៅមួយថ្ងៃ។ ដោយគិតថា **តើខ្ញុំជាគ្រីស្តបរិស័ទ ខ្ញុំធ្វើដូចម្តេចដើម្បីផ្តល់សក្ខីភាពនៃធម៌មេត្តាករុណា? តើខ្ញុំធ្វើដូចម្តេចដើម្បីណែនាំឲ្យបងប្អូននៅក្នុងភូមិរបស់ខ្ញុំអាចស្គាល់ពន្លឺថ្មីនៅក្នុងជីវិតផ្ទាល់ខ្លួនបាន?** ទេវទូតក៏ដូចជាព្រះនាងម៉ារីនិងសន្តសន្តី ដែលជាព្រះសហគមន៍នៅស្ថានបរមសុខគង់នៅជាមួយយើង ដើម្បីផ្តល់កម្លាំងឲ្យយើងណែនាំឲ្យយើងមានសេចក្តីសង្ឃឹមនៅក្នុងជីវិតគ្រប់ពេលវេលា។ យើងបានស្តាប់ទំនុកតម្កើងដែលយើងបានសូត្រ "**ព្រះអង្គជាកម្លាំង ពូកែ**

**ខ្លាំងមិនគេចពួន ជាខែលការពារខ្ញុំឲ្យមានជ័យ ខ្ញុំឡើងអរសប្បាយ ស្រស់រីករាយ លែងភិតភ័យ បានទ្រង់ជាបន្ទាយ សម្រាប់ជួយនឹងពឹងពាក់"** នេះជារបៀបដែលទេវទូតការពារយើង។ ទេវទូតបានណែនាំឲ្យយើងពោរពេញដោយអំណរសប្បាយ លែងភ័យខ្លាយ ដោយដឹងថាពិតមែនយើងអាចទីពឹងលើព្រះជាម្ចាស់ នៅគ្រប់កាលៈទេសៈនៃជីវិតរបស់យើង។

ខ្ញុំសូមអធិដ្ឋានឲ្យទេវទូតទាំងឡាយ ឲ្យព្រះជាម្ចាស់ ឲ្យព្រះនាងម៉ារីនិងសន្តសន្តីបុគ្គលទាំងអស់ ការពារថែរក្សាព្រះសហគមន៍របស់យើង ដើម្បីឲ្យយើងថែរក្សាជានិច្ចនូវគោលដៅស្រឡាញ់គ្នាទៅវិញទៅមកដូចព្រះយេស៊ូបានស្រឡាញ់យើង និងដើម្បីឲ្យយើងអនុវត្តនៅក្នុងជីវិតរបស់យើងយ៉ាងជាក់ស្ដែង ឲ្យព្រះសហគមន៍របស់យើងទៅជាពន្លឺដ៏តូចមួយ ដែលមានពន្លឺភ្លឺខ្លាំងសម្រាប់បងប្អូនឯទៀតៗនៅជុំវិញយើង។ យើងអរព្រះគុណព្រះជាម្ចាស់ សម្រាប់គ្រប់ស្នាដៃដែលព្រះជាម្ចាស់ណែនាំឲ្យយើងមាន យើងបន្តនៅក្នុងអំណរសប្បាយដោយសុំឲ្យព្រះជាម្ចាស់ប្រទានពរលើទេវទូតទាំងពីរនេះ លើយើងទាំងអស់គ្នាដែលមានទេវទូតម្នាក់ៗការពារយើង។ អាម៉ែន៕